ក្រុមប្រឹក្សាអាជ្ញាកណ្ដាល
THE ARBITRATION COUNCIL

**លេខ និង ឈ្មោះសំណុំរឿង : ០៩/១១-អិម វៃ (សាខាទី១)**

**កាលបរិច្ឆេទនៃសេចក្ដីបង្គាប់ : ថ្ងៃទី២១ ខែមករា ឆ្នាំ២០១១**

# សេចក្ដីបង្គាប់អាជ្ញាកណ្ដាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្ដីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្ដាល

អាជ្ញាកណ្ដាលជ្រើសរើសឡើងដោយភាគីនិយោជកៈ **ម៉ារ សំបូរណា**

អាជ្ញាកណ្ដាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិតៈ **អន ណន**

ប្រធានក្រុមអាជ្ញាកណ្ដាលជ្រើសរើសឡើងដោយអាជ្ញាកណ្ដាលទាំងពីរខាងលើៈ **គង់ ផល្លះ**

## ភាគីនៃវិវាទ

១- **ភាគីនិយោជក**

ឈ្មោះ : **ក្រុមហ៊ុន អិម វៃ កាត់ដេរអន្តរជាតិ លីមីធីត (សាខាទី១)**

អាសយដ្ឋាន : ផ្លូវជាតិលេខ ២ សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ : ០១៦ ៧០៧ ០៤៦ ទូរសារ : គ្មាន

តំណាងភាគីនិយោជក :

- លោក យិន ណាក់ រដ្ឋបាល

២- **ភាគីកម្មករនិយោជិត**

ក/.ឈ្មោះ : ~ **សហព័ន្ធសហជីពឯកសារហកម្មករកម្ពុជា**

~ **សហជីពឯករាជ្យសហកម្មករកម្ពុជា នៃក្រុមហ៊ុន អិម វៃ (សាខាទី១)**

អាសយដ្ឋាន : ផ្លូវជាតិលេខ ២ សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ

លេខទូរស័ព្ទ : ០១២ ៦៩៩ ៣៩៥ ទូរសារ : គ្មាន

តំណាងកម្មករនិយោជិត:

| | |
|---|---|
| ១- លោក ហែម សុខពន្លក | ប្រធានសហព័ន្ធសហជីពឧស្សាហកម្មកម្ពុជា |
| ២- លោក ទិត្យ សុខច័ន្ទ | អនុប្រធានសហព័ន្ធសហជីពឧស្សាហកម្មកម្ពុជា |
| ៣- លោកស្រី ចាន់ ធី | ប្រធានសហជីពឧស្សាហកម្មកម្ពុជា ប្រចាំរោងចក្រ |

ខ/.ឈ្មោះ : ~ **សហព័ន្ធសហជីពឯករាជ្យកម្មករកម្ពុជា**

~ **សហជីពឯករាជ្យកម្មករកម្ពុជា នៃក្រុមហ៊ុន អិម វ៉េ (សាខាទី១)**

អាសយដ្ឋាន : ផ្លូវជាតិលេខ ២ សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ : ០១២ ៨៨៤ ០៥៧ ទូរសារ : គ្មាន

តំណាងកម្មករនិយោជិត:

- លោកស្រី សៀន ស៊ីវន ប្រធានសហជីពឯករាជ្យកម្មករកម្ពុជាប្រចាំរោងចក្រ

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- ចំពោះកម្មការិនីដែលធ្វើការតាមបរិមាណផលិតផល នៅពេលចេញទៅបំបៅដោះកូនដែលក្រុមហ៊ុនអនុញ្ញាតឱ្យមួយម៉ោងនោះ សូមឱ្យក្រុមហ៊ុនយកប្រាក់ឈ្នួលសរុបដែលគាត់ផលិតបាន ចែករកមធ្យមភាគក្នុងមួយម៉ោង រួចហើយគិតប្រាក់ជូនគាត់ទៅតាមម៉ោងដែលក្រុមហ៊ុនអនុញ្ញាត។ ដោយឡែកភាគីក្រុមហ៊ុនសុំអនុវត្តតាមគោលការណ៍កន្លងមក ។

២- កម្មករនិយោជិតសូមឱ្យក្រុមហ៊ុនធ្វើការគណនាប្រាក់ឈប់សម្រាកប្រចាំឆ្នាំរបស់កម្មករនិយោជិត ដោយយកមធ្យមភាគនៃប្រាក់ឈ្នួលសរុបរយៈពេល ១២ ខែ ចុងក្រោយ ជាមូលដ្ឋាននៃការគណនាក្នុងកំឡុងពេលដែលកម្មករឈប់សម្រាក។ ដោយឡែកភាគីក្រុមហ៊ុនសុំអនុវត្តតាមគោលការណ៍កន្លងមក ។

៣- កម្មករនិយោជិតសូមឱ្យក្រុមហ៊ុនកាត់ប្រាក់រង្វាន់សមាមាត្រទៅនឹងថ្ងៃដែលកម្មករនិយោជិតអវត្តមានការងារដោយមានការអនុញ្ញាតពីនិយោជក។ ដោយឡែកភាគីក្រុមហ៊ុនសុំអនុវត្តតាមគោលការណ៍កន្លងមក។

៤- កម្មករនិយោជិតសុំទាមទារឱ្យក្រុមហ៊ុនត្រូវផ្តល់ប្រាក់ឈ្នួលជូនកម្មករផ្នែកប៉ះចំនួន ២៥ នាក់ ចាប់ពីថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១០ មកដល់ថ្ងៃដែលមានដំណោះស្រាយបញ្ចប់វិវាទ ។ ដោយឡែកភាគីក្រុមហ៊ុនមិនអាចផ្តល់ប្រាក់ឈ្នួលជូនដល់កម្មករនិយោជិតផ្នែកប៉ះចំនួន ២៥ នាក់នោះបានទេ ដោយសារមូលហេតុដូចខាងក្រោម :

ក-បងប្អូនទាំងនោះធ្វើកូដកម្មពីថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១០ រហូតមកដល់ឥឡូវនេះ ។

ខ-ក្រុមហ៊ុនដាក់ទំនិញរហូត តែបងប្អូនកម្មករនិយោជិតមិនព្រមធ្វើ ។

គ-ក្នុងចំណោមកម្មករផ្នែកប៉ះទាំងអស់ចំនួន ៤៥ នាក់ មានតែពួកគាត់ ២៥ នាក់ហ្នឹងទេ ដែលមិនព្រមធ្វើការតាមការរៀបចំបែងចែករបស់ក្រុមហ៊ុន ។

ឃ-ម្យ៉ាងទៀតករណីរឿងហ្នឹង ក្រុមហ៊ុនបានអញ្ជើញក្រសួងទៅដោះស្រាយនៅក្រុមហ៊ុនរួចហើយ នៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១០ ហើយបានបញ្ជូនទៅក្រុមប្រឹក្សាអាជ្ញាកណ្តាលទៀត តែត្រូវបងប្អូនដកបណ្តឹងនោះទៅវិញ នោះបង្ហាញឱ្យឃើញថា បងប្អូនមានចេតនាអាក្រក់ក្នុងការបង្កភាពរញ៉េរញ៉ៃក្នុងក្រុមហ៊ុនដែលអាចប៉ះពាល់យ៉ាងធ្ងន់ធ្ងរចំពោះវិធានខាងវិន័យ (ប៉ះពាល់ខ្សែសង្វាក់ផលិតកម្ម) ។

៥- កម្មករនិយោជិតសុំឱ្យក្រុមហ៊ុនផ្តល់សិទ្ធិជូនដល់កម្មករ នៅពេលសុំច្បាប់ឈប់មានធុរៈឱ្យមានលក្ខណៈស្រួលបានដូចមុន ។ ដោយឡែកភាគីក្រុមហ៊ុនបញ្ជាក់ថា ក្រុមហ៊ុននឹងអនុញ្ញាតច្បាប់មានធុរៈចាំបាច់ដល់កម្មករនិយោជិត បើក្រុមហ៊ុនពិនិត្យឃើញថា មិនប៉ះពាល់ដល់ខ្សែសង្វាក់ផលិតកម្ម និងផ្អែកលើកម្មករនិយោជិតមានមូលហេតុច្បាស់លាស់ ។

៦- កម្មករនិយោជិតសុំឱ្យក្រុមហ៊ុនផ្តល់ទំនិញធ្វើឱ្យបានគ្រប់គ្រាន់សម្រាប់កម្មករនិយោជិតដែលមានអតីតភាពច្រើនឆ្នាំ (កម្មករចាស់ )មុននឹងយកទៅឱ្យកម្មករនិយោជិតដែលមានកិច្ចសន្យាខ្លី១ធ្វើ និងដឹកចេញទៅខាងក្រៅ ។ ដោយឡែកភាគីក្រុមហ៊ុនបញ្ជាក់ថា ក្រុមហ៊ុនផ្តល់ទំនិញផ្នែកប៉ះធ្វើគ្រប់គ្រាន់ ដោយឡែកកម្មករដែលមានអតីតភាពយូរឆ្នាំ ពួកគាត់ជ្រើសរើសយកទំនិញណាដែលងាយស្រួលធ្វើ ទុកទំនិញណាដែលពិបាកឱ្យកម្មករដែលមានកិច្ចសន្យាខ្លីធ្វើ (បញ្ជាក់: ក្រុមហ៊ុនផ្តល់ទំនិញធ្វើទាំងងាយស្រួល និងពិបាកដល់កម្មករនិយោជិតទាំងអស់ធ្វើគ្រប់១គ្នា ) ។

៧- កម្មករនិយោជិតសុំឱ្យក្រុមហ៊ុនកុំរើសអើងទៅលើកម្មករដែលមានអតីតភាពច្រើនឆ្នាំឡើង ។ ដោយឡែកភាគីក្រុមហ៊ុនបញ្ជាក់ថា ក្រុមហ៊ុនពុំដែលមានការរើសអើងទៅលើកម្មករនិយោជិតណាម្នាក់ឡើយ ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ(ខ)( មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៣៣ កប/ប្រក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១០ ( អាណត្តិទី៨) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ ( ក) នៃច្បាប់ស្តីពីការងារ ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ

៦

ហើយរបាយការណ៍ស្តីអំពីការមិនសះជា លេខ ០៤១ កប/អក/វក ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១។

**សវនាការ និង សង្ខេបនីតិវិធី**

**ទីកន្លែងសវនាការ** : ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទជួបប្រជុំមុនសវនាការ** : ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១ ( វេលាម៉ោង ១៦:៣០ នាទី រសៀល ) ។

**បញ្ហានៃនីតិវិធី:**

នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១០ នាយកដ្ឋានវិវាទការងារបានទទួលពាក្យបណ្តឹងរបស់សហព័ន្ធសហជីពឧស្សាហកម្មកម្ពុជា និងសហព័ន្ធសហជីពឯករាជ្យកម្មករកម្ពុជា ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១០ ទាមទារឱ្យក្រុមហ៊ុនកែលំអលក្ខខណ្ឌការងារឱ្យបានល្អប្រសើរ។ បន្ទាប់ពីបានទទួលពាក្យបណ្តឹងនេះមក នាយកដ្ឋានវិវាទការងារបានចាត់តាំងមន្ត្រីជំនាញធ្វើការដោះស្រាយវិវាទការងាររួមនេះ និងផ្សះផ្សានៅថ្ងៃទី០៥ ខែមករា ឆ្នាំ២០១១ ដោយទទួលបានលទ្ធផលមិនសះជានឹងគ្នាចំនួន ០៧ ចំណុច លើការទាមទារចំនួន ០៨ ចំណុច។ ចំណុចមិនសះជាចំនួន ០៧ ចំណុចត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១។

ក្រោយពីទទួលរបាយការណ៍មិនសះជារបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទទួលដំណឹងតាមរយៈលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលពីភាគីនិយោជកថា ភាគីកម្មករនិយោជិតនៅផ្នែកប៉ះចំនួន ៥១ នាក់ កំពុងធ្វើកូដកម្ម ប៉ុន្តែ ភាគីកម្មករនិយោជិតបានបញ្ជាក់ថា ពួកគាត់មិនបានធ្វើកូដកម្មនោះទេ។

នៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០១១ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានស្នើឱ្យលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលអញ្ជើញភាគីកម្មករនិយោជិត និងភាគីនិយោជក មកជួបប្រជុំជំហ៊ានដំបូងមុនថ្ងៃសវនាការ នៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០១១។

នៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០១១ ភាគីកម្មករនិយោជិត និងនិយោជកមានវត្តមានតាមការកោះអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ នៅក្នុងការជួបប្រជុំជំហ៊ានដំបូងមុនថ្ងៃសវនាការនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានសាកសួរភាគីភាគីកម្មករនិយោជិត ដើម្បីធ្វើការបញ្ជាក់ឱ្យបានច្បាស់ថា តើភាគីកម្មករនិយោជិតកំពុងធ្វើកូដកម្ម ឬទេ? ភាគីកម្មករនិយោជិតបានបដិសេធថា មិនមានកូដកម្មកើតឡើងនៅផ្នែកប៉ះនោះទេ ប៉ុន្តែកម្មករនិយោជិតទទួលស្គាល់ថា ក្រុមហ៊ុនមានការងារឱ្យធ្វើ ប៉ុន្តែកម្មករនិយោជិតមិនធ្វើការ ហើយអង្គុយនៅតាមផ្នែករបស់ខ្លួន (ផ្នែកប៉ះ) ដោយសារតែក្រុមហ៊ុនមិនបានដោះស្រាយបញ្ហាដែលពួកគេទាមទារពីមុនមក។

6

ចំណែកឯនិយោជកនិយាយថា ករណីនេះជាកូដកម្ម ព្រោះក្រុមហ៊ុនមានការងារឱ្យធ្វើ តែកម្មករនិយោជិតមិនព្រមធ្វើការ ។

នៅក្នុងការជួបប្រជុំនេះ និងក្រោយពីបានស្តាប់ភាគីទាំងពីរ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមពន្យល់ភាគីអំពីនីតិវិធីរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ដោយស្នើសុំឱ្យភាគីកម្មករនិយោជិត បន្តបំពេញការងារជាធម្មតាវិញ ដោយជៀសវាងវិធានការទាំងឡាយណា ដែលនាំឱ្យស្ថានភាពវិវាទកាន់តែធ្ងន់ធ្ងរ ដើម្បីឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចបន្តនីតិវិធីដោះស្រាយវិវាទនេះតាមផ្លូវច្បាប់ ។

នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០១១ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទទួលដំណឹងតាមរយៈលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលថា ភាគីកម្មករនិយោជិតផ្នែកប៉ះនៅតែបន្តមិនធ្វើការ ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីបញ្ជាជាបន្ទាន់ ដើម្បីឱ្យភាគីកម្មករនិយោជិតផ្អាកការធ្វើកូដកម្ម (មិនបំពេញការងារ) រហូតដល់នីតិវិធីនៃអាជ្ញាកណ្តាលត្រូវបានបញ្ចប់សព្វគ្រប់តាមនីតិវិធី ។ នៅក្នុងសេចក្តីបញ្ជានេះបញ្ជាក់ថា កម្មករនិយោជិតត្រូវត្រឡប់ចូលធ្វើការវិញ ចាប់ពីម៉ោង ១២:៣០ នាទី រសៀល ថ្ងៃទី១៨ ខែមករា ឆ្នាំ២០១១ តទៅ។ និយោជកត្រូវបន្តផ្តល់ការងារជាធម្មតាជូនកម្មករនិយោជិតដែលធ្វើកូដកម្មទាំងនោះ ។ នៅវេលាប្រហែលម៉ោង ៣ រសៀល ថ្ងៃដដែល ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទទួលដំណឹងតាមរយៈលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលថា ភាគីកម្មករនិយោជិតមិនបានត្រឡប់ចូលធ្វើការតាមសេចក្តីបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនោះទេ ហើយនៅតែបន្តអង្គុយស្ងៀមមិនធ្វើការងារដដែល ។

ហេតុនេះហើយ នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា ដូចខាងក្រោម:

## ភស្តុតាង

សាក្សី និង អ្នកជំនាញក្រៅពីភាគី : គ្មាន

## ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន

### ក- ឯកសារបានទទួលពីភាគីនិយោជក :

១- លិខិតរបស់នាយកក្រុមហ៊ុន អិម វ៉េ គោរពជូនក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសំណើរសុំចេញសេចក្តីបញ្ជា ដើម្បីផ្អាកការធ្វើកូដកម្មរបស់កម្មករនិយោជិតផ្នែក ប៉ះអាវ នៅក្រុមហ៊ុន អិម វ៉េ (សាខាទី១) ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១១ ។

២- លិខិតដកពាក្យបណ្តឹងសម្រាប់សំណុំរឿង ១៣៤/១០ របស់តំណាងកម្មករនិយោជិតផ្នែកប៉ះ នៃក្រុមហ៊ុន អិម វ៉េ (សាខាទី១) ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១០ ។

### ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត : គ្មាន

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន អិម វ៉េ ទី១ លេខ ០៤១ កប/អក/វក ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន អិម វ៉េ ទី១ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ ២០១១។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមផ្តល់ព័ត៌មាន លេខ ០៤៥ កប/អក/វក/លកអ. ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១១។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមផ្តល់ព័ត៌មានលេខ ០៤៦ កប/អក/វក/លកអ. ចុះថ្ងៃទី ១៤ ខែមករា ឆ្នាំ២០១១។

## អង្គហេតុ

មិនមានការរកឃើញអង្គហេតុទាក់ទងទៅនឹងចំណុចវិវាទ នៅក្នុងរបាយការណ៍មិនសះជា ដែលក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ ដោយសារសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចដំណើរការទៅបាន។

## ហេតុផលនៃសេចក្តីសម្រេចៈ

នៅក្នុងសំណុំរឿងនេះ កម្មករនិយោជិតបានទទួលស្គាល់ថា ក្រុមហ៊ុនមានការងារឱ្យធ្វើ ប៉ុន្តែ កម្មករនិយោជិតមិនធ្វើការ ហើយអង្គុយនៅតាមផ្នែករបស់ខ្លួន (ផ្នែកប៉ះ) ដើម្បីទាមទារក្រុមហ៊ុនដោះស្រាយបញ្ហាដែលពួកគាត់បានទាមទារពីមុនមក ។

យោងមាត្រា ៣១៨ នៃច្បាប់ស្តីពីការងារបានចែងថា *" កូដកម្ម គឺជាកាឈប់ធ្វើការងារ ដោយកម្មករនិយោជិតមួយក្រុម......... ក្នុងគោលបំណង ដើម្បីទទួលបាននូវដំណោះស្រាយដ៏យុត្តិធម៌ចំពោះការទាមទាររបស់កម្មករនិយោជិតពីនិយោជក........ ។"*

ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា សកម្មភាពរបស់កម្មករនិយោជិតដែលអង្គុយនៅស្ងៀមមិនធ្វើការនៅកន្លែងការងារ ហើយទាមទារក្រុមហ៊ុនដោះស្រាយបញ្ហាដែលពួកគាត់បានទាមទារពីមុនមក គឺជាកូដកម្ម ផ្អែកតាមមាត្រា ៣១៨ ខាងលើ ។

យោងតាមប្រការ ២០ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចែងថា *"ក្នុងអំឡុងពេលនៃដំណើរការរបស់ក្រុមអាជ្ញាកណ្តាល ភាគីវិវាទទាំងឡាយ*

6

*ត្រូវផ្អាករាល់វិធានការវិវាទ ដូចជា កូដកម្ម ឬឡុកអៅ (ដូចមានចែងក្នុងមាត្រា ៣១៨ នៃច្បាប់ស្តីពីការងារ) ឬវិធានការដទៃទៀត ដែលអាចធ្វើឱ្យស្ថានភាពវិវាទកាន់តែធ្ងន់ធ្ងរ។ ភាគីទាំងនេះត្រូវតែចូលរួមគ្រប់កិច្ចប្រជុំទាំងឡាយ ដែលក្រុមអាជ្ញាកណ្តាលបានអញ្ជើញឱ្យចូលរួម។"*

បន្ថែមលើនេះទៀត នៅក្នុងសេចក្តីបង្គាប់មុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយមាត្រានេះថា ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងមិនបន្តដំណើរការអាជ្ញាកណ្តាលទេ នៅពេលណាភាគីកម្មករនិយោជិតកំពុងធ្វើកូដកម្ម ឬនិយោជកធ្វើឡុកអៅ។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាល លេខ ៥៩/០៦-សាង វ៉ី, លេខ ៣៩/០៨-ចុង យូ, លេខ ១៣៧/០៩ និង លេខ ១៣៨/០៩-ញូ ភាញ់ និង លេខ ១០៣/១០-វ៉ាយចិច)*។

ទាក់ទងនឹងការធ្វើកូដកម្មរបស់កម្មករនិយោជិត នៅក្នុងពេលដំណើរការក្រុមប្រឹក្សាអាជ្ញាកណ្តាលនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងនេះ បានរកឃើញយុត្តិសាស្ត្ររបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅក្នុងសំណុំរឿងមុនៗ ដូចខាងក្រោម៖

នៅក្នុងសេចក្តីបង្គាប់អាជ្ញាកណ្តាល លេខ ០៤/០៤-អិម អេស អាយ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីជូនដំណឹងមួយ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៤ ដែលកថាខ័ណ្ឌទី៤ នៃសេចក្តីជូនដំណឹងនេះ ចែងថា *"ដោយពិនិត្យឃើញថា ភាគីនៃវិវាទការងារនេះមិនមានសិទ្ធិធ្វើកូដកម្ម ក្នុងកំឡុងពេលនៃដំណើរការរបស់អាជ្ញាកណ្តាល ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចធ្វើការដោះស្រាយ ឬក៏ចេញសេចក្តីបង្គាប់លើវិវាទការងាររួម ដែលបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលនេះឡើយ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចដោះស្រាយវិវាទការងាររួមនេះម្តងទៀតបាន នៅពេលណាដែលសហជីព កម្មករនិយោជិតទាំងអស់ឈប់ធ្វើកូដកម្ម។"*

នៅក្នុងសំណុំរឿងលេខ ៧៧/០៥-ហ្វ្រង់កូ នីតធីង ហ្វាមេន ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីបញ្ជា ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០៥ ហើយបានចែងនៅក្នុងចំណុចទី៤ ថា *" នៅក្នុងករណីដែលភាគីកម្មករនិយោជិតបន្តធ្វើកូដកម្ម ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងមិនដំណើរការដោះស្រាយវិវាទការងាររួមនេះទេ "*

នៅក្នុងសំណុំរឿងលេខ ២៨/០៦-ជី ឌី អឹម និងសំណុំរឿងលេខ ៣៤/០៦-ហ្គោល ហ្វេម ក្រុមប្រឹក្សាអាជ្ញាកណ្តាល ក៏បានចេញសេចក្តីបង្គាប់បិទសំណុំរឿងទាំងនោះ ដោយមូលហេតុថា កម្មករនិយោជិតនៅតែបន្តធ្វើកូដកម្មក្នុងអំឡុងពេលដំណើរការនីតិវិធីរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល *(សូមមើលបន្ថែមក្នុងសេចក្តីបង្គាប់អាជ្ញាកណ្តាល លេខ ៩៧/០៧-ស៊ូត វ៉ី, លេខ ៦៣/០៨-សៅធន៍ ប៊េរ និង ហ្គោលដិន ហ្គ្រោន)*។

ផ្អែកលើការបកស្រាយខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីកម្មករនិយោជិត នៅក្នុងសំណុំរឿងលេខ ០៩/១១-អិម វ៉ី (សាខាទី១) នេះ ពុំបានបង្ហាញពីចេតនាពិតប្រាកដណាមួយថា ភាគីកម្មករនិយោជិតមានបំណងយកវិវាទការងាររួមនេះ មកដោះស្រាយនៅក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ ព្រោះ ភាគីកម្មករនិយោជិតនៅតែបន្តធ្វើកូដកម្ម ដោយមិនគោរពតាមសេចក្តីបញ្ជា និងការស្នើសុំរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ។

ហេតុដូច្នេះ ដោយផ្អែកទៅលើច្បាប់ ព្រមទាំងសេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចថា មិនបន្តដំណើរការអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះទេ។

យោងតាមហេតុផលខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច ដូចតទៅ :

**សម្រេច និង បង្គាប់**

បិទសំណុំរឿងលេខ ០៩/១១-អិម វ៉ៃ (សាខាទី១) ។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក :**

ឈ្មោះ : **ម៉ា រ សំបូរណា**

ហត្ថលេខា: ------------------------------

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត :**

ឈ្មោះ : **អន ណាន**

ហត្ថលេខា: ------------------------------

**ប្រធានក្រុមអាជ្ញាកណ្តាល :**

ឈ្មោះ : **គង់ ផល្លៈ**

ហត្ថលេខា: ------------------------------